ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**យូនីត (ខេមបូឌា) ខូអេលធីឌី**

**U-KNITS (CAMBODIA) CO., LTD**

អាស័យដ្ឋាន: ផ្លូវជាតិលេខ២ ភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល

# កិច្ចព្រមព្រៀង

**ស្តីពីការប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល០៧ថ្ងៃ គឺចាប់ពីថ្ងៃទី០៦ ខែមករា ដល់ថ្ងៃទី១២ ខែ មករា ឆ្នាំ២០២៣**

*អង្គប្រជុំបានឯកភាព និងព្រមព្រៀងដូចខាងក្រោម៖*

នៅថ្ងៃអង្គារ៥រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោងដប់បីរសៀល មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន យូនីត (ខេមបូឌា) ដែលមានអាស័យដ្ឋានស្ថិតនៅផ្លូវជាតិលេខ២ ភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលមានកម្មករសរុប ៩៥៧នាក់ (ស្រី៧៥១) ដែលមានលោកស្រី JI SEUNG HEE ជាអ្នកគ្រប់គ្រងទូទៅ តំណាងអោយលោក SOHN CHHON IK ជនជាតិកូរ៉េ ជានាយកក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ បានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករចំនួន០៧ថ្ងៃ ។

ជាកិច្ចចាប់ផ្តើមលោកស្រី JI SEUNG HEE ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំថ្ងៃនេះ បន្ទាប់មកលោកប្រធាន អង្គប្រជុំបានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់ពីមូលហេតុដោយសារតែក្រុមហ៊ុន ខ្វះការបញ្ជាទិញ ដូច្នេះក្រុមហ៊ុន យូនីត (ខេមបូឌា) និងតំណាងប្រតិភូបុគ្គលិក និងសហជីពនៃកម្មករនិយោជិតទាំងអស់បានព្រមព្រៀងគ្នាដូចខាងក្រោម:

១. ឯកភាពព្យួរកិច្ចសន្យាការងារកម្មករចំនួន ៩៥៧នាក់ រយៈពេល០៧ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៦ ខែមករា រហូតដល់ថ្ងៃទី១២ ខែមករា ឆ្នាំ ២០២៣។

២. ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុនបានព្រមព្រៀង ផ្តល់ប្រាក់ឧបត្ថមជូន កម្មករនិយោជិតគឺស្មើនឹង ៥០% នៃប្រាក់ខែគោល និងបើកប្រាក់ឧបត្ថម្ភ ៥០% នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣។

ថ្ងៃអង្គារ៥រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

តាខ្មៅ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២

| បានឃើញ និងឯកភាព | បានឃើញ និងឯកភាព | |
|---|---|---|
| តំណាងសហជីព | ប្រតិភូបុគ្គលិក (តំណាងកម្មករ) | **នាយកក្រុមហ៊ុន** |

តំណាងសហជីព:
- សុខ គឹមសាន
- សុត ច័ន្ទតារា
- ហ៊ិន ចាន់រី

ប្រតិភូបុគ្គលិក (តំណាងកម្មករ):
- ម៉ន យុទ្ធា
- ហ៊ិន ចាន់រី
- ម៉ាយ សេដា
- ប៉ែន សារិទ្ធ
- ពៅ សុខរ៉េត
- ជឿន សម្បូរ
- លុន សុខរ៉ន
- សុត ច័ន្ទតារា
- ជាប សុខណា
- នាង ចាន្ធូ
- សោម ស្រីខួច

នាយកក្រុមហ៊ុន:

SOHN CHON IK